INTERNATIONAL DAY OF ACTION FOR RIVERS

# លិខិតចំហរៈ អនុសាសន៍ដើម្បីការពារបរិស្ថានទន្លេមេគង្គ

ទន្លេមេគង្គ ដែលល្បីល្បាញថាជាទន្លេជួយជីវិតមនុស្សរាប់លាននាក់ ដែលកំពុងរស់នៅក្នុងបរិវេនអាងទន្លេនោះ កំពុងបាត់បង់ប្រព័ន្ធអេកូឡូស៊ីដ៏ស្មុកស្មាញរបស់ខ្លួន ដោយសារតែគម្រោងអភិវឌ្ឍន៍ទំបន់វារីអគ្គីសនីនៅតាមដងទន្លេមេ និងដៃទន្លេ។ ក្នុងនាមជាប្រជាជនមូលដ្ឋាន ដែលបាន និងកំពុងរស់នៅក្នុងអាងទន្លេមេគង្គ ជាអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាល និងជាអ្នកស្រាវជ្រាវដែលមានក្តីកង្វល់ជុំវិញបញ្ហានេះ សូមផ្តល់នូវអនុសាសន៍មួយចំនួន ជូនដល់រដ្ឋាភិបាលនៃប្រទេសតាមដងទន្លេមេគង្គ ប្រទេសម្ចាស់ជំនួយ និងពលរដ្ឋដែលរស់នៅក្នុងអាងទន្លេ មេគ្គាធ្វើយ៉ាងណាធានាឲ្យបាននូវនិរន្តរភាពបរិស្ថានរបស់ទន្លេមេគង្គ។

ក្នុងចំណោមប្រជាជនប្រមាណ៦០លាននាក់ ដែលកំពុងរស់នៅក្នុងអាងទន្លេមេគង្គ ប្រហែលមានប្រជាជន ៨០% រស់នៅតាមតំបន់ជនបទ និងពឹងអាស្រ័យលើរបរកសិកម្ម ការនេសាទ ការដកហូត/ប្រមូលផលធនធានទន្លេ ទាំងសត្វ និងរុក្ខជាតិ ដើម្បីចិញ្ចឹមជីវិត។ ធនធានត្រី ពីទន្លេមេគង្គ មានសារៈសំខាន់ណាស់សម្រាប់ប្រជាជនក្នុងតំបន់ ពីព្រោះវាជាប្រភពប្រូតេអ៊ីនដ៏ចាំបាច់ និងមានតម្លៃថោកសមរម្យ។ ម្យ៉ាងទៀត វាក៏ជាប្រភពប្រាក់ចំនូលដ៏សំខាន់ផងដែរ។ ផលចាប់នៃធនធានជលផលពីអាងទន្លេមេគង្គ មានតម្លៃប្រមាណពី ៤.២ ដល់ ៧.៦ ពាន់លានដុល្លារសហរដ្ឋអាមេរិក បើគិតតាមតម្លៃទីផ្សារលក់រាយ។ តាមដឹង ប្រហែលមានមនុស្ស ៤០ លាននាក់

ដោយរាប់បញ្ចូលទាំងអ្នកធ្វើការក្រៅម៉ោង ឬការងារតាមរដូវកាលផង ភ្ជាប់ជីវិតរបស់ពួកគេជាមួយការនេសាទនៅក្នុងប្រព័ន្ធទន្លេខ្វាត់ខ្វែងនៃអាងទន្លេមេគង្គ។

ថ្ងៃនេះ ទន្លេមេគង្គបានជួបនូវវិបត្តិមួយដ៏ធ្ងន់ធ្ងរ។ ទំនប់វារីអគ្គីសនីខ្នាតយក្សចំនួន៦ ដែលស្ថិតនៅខ្សែទឹកភាគខាលើនៃទន្លេមេគង្គក្នុងប្រទេសចិន បានចាប់ផ្ដើមដំណើរការផលិតថាមពលរបស់ខ្លួនហើយ។ មានទំនប់វារីអគ្គីសនីជាច្រើនទៀតត្រូវបានសាងសង់កាត់ទន្លេ ដូចជាកាត់ដៃទន្លេមេគង្គចំនួន៦នៅក្នុងប្រទេសឡាវ កាត់ទន្លេមូនក្នុងប្រទេសថៃ និងដៃរបស់វា គឺទន្លេឈី កាត់ទន្លេសេកុង ទន្លេស្រែពក និងទន្លេសេសាន ដែលហូរពីប្រទេសវៀតណាម និងប្រទេសឡាវចូលមកប្រទេសកម្ពុជា។ ជាងនេះទៀត ប្រទេសឡាវកំពុងបន្តដំណើររបស់ខ្លួនឆ្ពោះទៅរកការសាងសង់ទំនប់សាយ៉ាប៊ូរី (Xayaburi) និងទំនប់ដនសាហុង (Don Sahong) នៅលើដងទន្លេមេនៃទន្លេមេគង្គ។ អ្នកវិទ្យាសាស្ត្រជាច្រើន រំពឹងថា ទំនប់ដនសាហុងនេះ និងទំនប់សេសានក្រោម២នៅប្រទេសកម្ពុជា ដែលកំពុងសាងសង់ នឹងបង្កវិនាសកម្មធ្ងន់ធ្ងរមួយកម្រិតទៀត ដល់ធនធានត្រីដែលកំពុងតែមានតិចតួចស្រាប់នៅក្នុងអាងទន្លេមេគង្គ។

ឥទ្ធពលពីការអភិវឌ្ឍន៍ទំនប់វារីអគ្គីសនី បានបង្កឲ្យមានការខូចខាតយ៉ាងធំធេង។ នៅពេលដែលលំហូរធម្មជាតិរបស់ទន្លេ ត្រូវបានបង្ខាំងដោយទំនប់ ល្បាប់ភក់ដ៏មានជីជាតិរបស់ទន្លេមេគង្គ ត្រូវស្ទះដំណើរមិនអាចហូរចុះមកកាន់ផ្នែកខាងក្រោមបាន ដែលធ្វើឲ្យកខ្វក់ដល់គុណភាពទឹកនៅក្នុងផ្ទៃអាងស្តុបទឹករបស់ទំនប់ និងចុងបញ្ចប់ត្រូវក្លាយជាកំណកភក់នៅទីនោះតែម្តង។ ក្នុងរយះពេល២០ឆ្នាំចុងក្រោយនេះ

ចំនួនកករត្រឹមតែពាក់កណ្តាលប៉ុណ្ណោះ ដែលអាចហូរឆ្ពោះទៅដល់ទីប្រសព្វរវាងទឹកសាប និងទឹកប្រៃនៃតំបន់ដីសណ្តទន្លេមេគង្គបាន។ បន្ថែមពីលើនេះ ទំនប់ក៏បានរារាំងដំណើរពងកូនរបស់អំបូរត្រីមួយចំនួនផងដែរ ថែមទាំងមិនអាចឲ្យពួកវារកទីជម្រក និងអាហារបានទៀតផង ដែលនៅទីបញ្ចប់ធនធានត្រីត្រូវវិនាសហិនហោច។ សម្រាប់ប្រភេទត្រីមួយចំនួនក្នុងទន្លេមេគង្គ ទឹកឡើងតាមធម្មជាតិនៅរដូវវស្សា គឺជាលក្ខខណ្ឌជំរុញដល់ការពងកូនរបស់ពួកវា។ ទោះជាយ៉ាងនេះក្តី លក្ខខណ្ឌជំរុញនេះ លែងដំណើរការ ចំណែកការពងកូនរបស់ត្រីក៏ត្រូវបាត់បង់ផងដែរ ដោយសារតែការទប់ទឹករបស់ទំនប់។ លំហូរទឹកខុសប្រក្រតី និងការប្រែប្រួលគុណភាពទឹក បានបំផ្លាញដល់ពពួកសត្វល្អិត និងរុក្ខជាតិក្នុងទឹក ដែលជាប្រភពចំនីរបស់ត្រី។ ប្រជាជន ក៏រងផលប៉ះពាល់ពីទំនប់ដែរ។ ទំនប់បានបំផ្លាញកសិដ្ឋានដំណាំតាមមាត់ច្រាំងទន្លេ និងនៅកន្លែងប្រសព្វរវាងទឹកសាប និងទឹកប្រៃដែលនៅទីនោះ កសិដ្ឋានដំណាំភាគច្រើន គ្រប់គ្រងបន្តបន្ទាប់គ្នាពីមួយជំនាន់ទៅមួយជំនាន់។ នៅពេលដែលធនធានជលផលសម្រាប់ការប្រើប្រាស់ និងលក់ដូរធ្លាក់ចុះ សហគមន៍ដែលប្រកបរបរនេសាទ ត្រូវធ្លាក់ខ្លួនក្រីក្រ ឬត្រូវបាត់បង់អាជីពតែម្តងនៅតំបន់ខ្លះ។ តាមរយៈការរស់នៅរបស់សហគមន៍មូលដ្ឋានក្នុងអាងទន្លេមេគង្គ វាបានបញ្ជាក់យ៉ាងច្បាស់ថា ការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនី ក្នុងរយៈពេល៣០ឆ្នាំមកនេះ ពិតជាបានធ្វើឲ្យមានការខូចខាត និងការបាត់បងផ្សេងៗជាច្រើនពិតប្រាកដមែន។

បញ្ចូលសក្ខីភាព និងបទពិសោធន៍របស់សហគមន៍មូលដ្ឋាន៖

ឧទាហរណ៍៖

- ទន្លេមិនត្រឹមផ្តល់ទឹកសម្រាប់ប្រជាជនប្រើប្រាស់ប៉ុណ្ណោះទេ

វាថែមទាំងមានសារៈសំខាន់អាចធានាដល់សន្តិសុខស្បៀងផងដែរ

- ការសាងសង់ទំនប់វារីអគ្គីសនី ធ្វើអោយជំរកធម្មជាតិរបស់ត្រី និងបរិមាណត្រីធ្លាក់ចុះ ហើយរុក្ខជាតិដែលដុះក្នុងទឹកនឹងត្រូវបាត់បង់
- វប្បធ៌ម និងប្រពៃណីដែលផ្អែកលើទន្លេ កំពុងបាត់បង់ ចំណែកកូនៗរបស់យើងវិញ ក៏លែងមានឱកាសគោរព និងឲ្យតំលៃទន្លេទៀតដែរ
- ពិធីបុណ្យលក្ខណៈប្រពៃណីជាច្រើន ដែលត្រូវការទន្លេធ្វើជាទីកន្លែងគោរពសក្ការៈ ត្រូវបាត់បង់ដោយសារការអភិវឌ្ឍន៍ទំនប់អគ្គីសនី
- ត្រី មិនត្រឹមតែជាអាហារដែលទ្រទ្រង់ជីវិតមនុស្សម្នាក់ៗប៉ុណ្ណោះទេ វាក៏ជាទ្រព្យដែលអាចទ្រទ្រង់ដល់សហគមន៍ដ៏ធំផងដែរ
- ទន្លេមេគង្គ មិនមែនតែជាកម្មសិទ្ធិរបស់កសិករ និងប្រជាជនដែលរស់នៅជិតទន្លេទេ ប៉ុន្តែវាជាកម្មសិទ្ធិរបស់មនុស្សគ្រប់គ្នា។ ទន្លេមេគង្គ គឺជាទ្រព្យសម្បត្តិរួមរបស់មនុស្សគ្រប់រូប។
- ទឹក បាយ ត្រី និងអាហារធម្មជាតិដ៏ទៃទៀត គឺមានសារៈសំខាន់ណាស់ ជាពិសេសសម្រាប់សហគមន៍មូលដ្ឋាន។

សារៈសំខាន់នៃជីវៈចម្រុះ ត្រូវបានគេទទួលស្គាល់។ ទោះជាយ៉ាងនេះក្តី ការអភិវឌ្ឍន៍ទំនប់វារីអគ្គីសនីដែលផ្តល់ផលប៉ះពាល់ជាអវិជ្ជមានដល់ជីវៈចំម្រុះ នៅតែបន្ត។ នៅក្នុងអាងទន្លេមេគង្គខាងក្រោម មានគម្រោងសាងសង់ទំនប់ចំនួន១០ កាត់ទន្លេមេនៃទន្លេមេគង្គ និង១០០គម្រោង កាត់ដៃទន្លេមេគង្គ។ គម្រោងទាំងនេះភាគច្រើនដើម្បីផលិតថាមពលអគ្គីសនី។

នៅពេលដែលប្រភេទសត្វណាមួយដាច់ពូជ ជាការពិត គឺមនុស្សមិនអាចមានសមត្ថភាពនាំពួកវាត្រឡប់មកវិញបានទេ។ ម្យ៉ាងវិញទៀត

អគ្គិសនីអាចផលិតបានតាមមធ្យោបាយផ្សេងៗជាច្រើន ដូចជាតាមរយៈកំលាំងខ្យល់ និងពន្លឺព្រះអាទិត្យជាដើម។ គួរឲ្យសោកស្តាយ ការបំផ្លាញទន្លេ ត្រូវបានគេទទួលយក និងត្រូវប្តូរឈ្មោះទៅជាការអភិវឌ្ឍន៍សេដ្ឋកិច្ចទៅវិញ។ ផលចំណេញបានតែទៅលើក្រុមមនុស្សមួយចំនួនតូចដែលវិនិយោគលើគម្រោងនេះប៉ុណ្ណោះ ប៉ុន្តែផលលំបាកចេញពីការវិនិយោគដ៏ធំៗនេះវិញ ត្រូវធ្លាក់ទៅលើប្រជាជនសាមញ្ញដែលត្រូវគេបង្ខំឲ្យទិញអគ្គិសនីក្នុងតម្លៃខ្ពស់ ហើយដោយមិននិយាយដល់ផលប៉ះពាល់ផ្សេងៗ ពួកគេជាពិសេសសហគមន៍ក្នុងតំបន់ទំនប់ផ្ទាល់
ទទួលបានផលប្រយោជន៍តិចតួចបំផុតពីទំនប់។

យើងខ្ញុំ ក្នុងនាមជាសហគមន៍ដែលកំពុងរស់នៅក្នុងអាងទន្លេមេគង្គ ក៏ដូចជាជាប្រជាពលរដ្ឋពាក់ព័ន្ធផ្សេងៗ ដែលមានបំណងការពារជីវិតសហគមន៍ក្នុងអាងទន្លេនៅមិនទាន់បោះ បង់ក្តីសង្ឃឹមរបស់យើងនៅឡើយទេ។ ដើម្បីខ្លួនយើងខ្ញុំផ្ទាល់ និងដើម្បីក្មេងៗជំនាន់ក្រោយ យើងសូមលើកនូវអនុសាសន៍មួយចំនួនដូចខាងក្រោម៖

**ជូនចំពោះរដ្ឋាភិបាលរបស់ប្រទេសតាមទន្លេមេគង្គ៖**

- សូមពិនិត្យមើលឡើងវិញ និងលាតត្រដាងជាសាធារណៈ នូវផលប៉ះពាល់ដែលកើន ឡើងពីការអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីក្នុងអាងទន្លេមេគង្គទាំងមូល។ សូមរៀបចំវេទិកាជជែកពិភាក្សាដោយចំហរ អំពីអនាគតនៃតំបន់មេគង្គ និងយកលទ្ធផលនៃការពិភាក្សានេះទៅថ្លឹងថ្លែងជាមួយគោលនយោបាយ។
- សូមសិក្សាវាយតម្លៃឡើងវិញ នូវគ្រប់គម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គិសនីកាត់ទន្លេមេនៃទន្លេមេគង្គ និងដៃសំខាន់ៗរបស់វា។ សូមបញ្ឈប់ការប្រើប្រាស់ទំនប់ប្រសិនបើយល់ថាចាំបាច់ក្នុងការលើកកម្ពស់សុខុមាលភាពសង្គម

និងបរិស្ថានធម្មជាតិក្នុងអាងទន្លេ។

- សូមពិចារណាក្នុងការលុបចោលនូវគម្រោងការសាងសង់ទំនប់វារីអគ្គីសនីដនសាហុង (Don Sahong) និងទំនប់វារីអគ្គីសនីសេសានក្រោម២ (LS2)។
- សូមផ្តល់ជាសំណងដល់សហគមន៍មូលដ្ឋាន ចំពោះការខូចខាតផ្សេងៗ ផ្នែកសង្គម និងបរិស្ថាន ដែលបង្កឡើងដោយគម្រោងទំនប់ដែលមានស្រាប់។ សូមចាត់វិធានការណ៍ឲ្យបានត្រឹមត្រូវ ដើម្បីស្តារឡើងវិញនូវការខូចខាតផ្នែកសង្គម និងបរិស្ថាន។

## ជូនចំពោះប្រទេសម្ចាស់ជំនួយ និងអង្គការអន្តរជាតិពាក់ព័ន្ធ៖

- សូមធ្វើការជាមួយរដ្ឋាភិបាលរបស់ប្រទេសតាមទន្លេមេគង្គ ដើម្បីធានាឲ្យមានការចូលរួមពីសហគមន៍មូលដ្ឋាន ក្នុងការធ្វើសេចក្តីសម្រេចផ្សេងៗ របស់គណៈកម្មទន្លេមេគង្គ (MRC) ឬក្នុងក្របខណ្ឌទាំងឡាយណា ដែលធ្វើសេចក្តីសម្រេចផ្សេងៗពីការគ្រប់គ្រងអាងទន្លេមេគង្គ។
- សូមបញ្ឈប់យកមូលហេតុដែលថា ទំនប់វារីអគ្គីសនីបំភាយឧស្ម័នកាបូនិចតិច ($CO_2$) ទៅក្នុងបរិយាកាស ដើម្បីគាំទ្រដល់ការអភិវឌ្ឍន៍ទំបន់វារីអគ្គីសនី។ សូមជុំរុញ និងផ្តល់ហិរញ្ញបទានដល់ប្រភេទបណ្តាញ និងប្រព័ន្ធផលិតថាមពលថ្មីមួយ គឺបណ្តាញ និងប្រព័ន្ធផលិតថាមពលដោយកន្លែង (dispersed energy systems) ដែលត្រូវការកន្លែងតូចដើម្បីផលិតភ្លើងឲ្យស្របតាមតំបន់នីមួយៗ ជាជាងបណ្តាញផលិតថាមពលប្រមូលផ្តុំមួយកន្លែង (broad power networks) ដែលត្រូវការកន្លែងធំដើម្បីផលិតភ្លើងបានច្រើន ហើយត្រូវចែកចាយទៅឆ្ងាយរហូតដល់ក្រៅតំបន់របស់ខ្លួន។

- សូមផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុ ដល់កិច្ចខិតខំប្រឹងប្រែងស្តារឡើងវិញនូវការខូចខាតផ្នែកបរិស្ថានសង្គម និងធម្មជាតិ ដោយសារគម្រោងអភិវឌ្ឍន៍នានាដែលផ្តល់មូលនិធិគាំទ្រដោយម្ចាស់ជំនួយកាលពីអតីត។
- ជាជាងគ្រាន់តែធ្វើដើម្បីផលប្រយោជន៍ក្រុមហ៊ុនរបស់ប្រទេសខ្លួន សូមគាំទ្រ និងផ្តល់ហិរញ្ញបទានដល់កិច្ចខិតខំប្រឹងប្រែងណា ដែលចូលរួមចំណែកអភិរក្សបរិស្ថានរបស់សាកលលោក និងរក្សាស្ថេរភាពតំបន់។
- ជូនជាពិសេសដល់រដ្ឋាភិបាលម្ចាស់ជំនួយ ដែលលេចមុខថ្មីៗមកគាំទ្រថវិកាដល់គម្រោងអភិវឌ្ឍន៍ទំនប់វារីអគ្គីសនីនៅក្រៅប្រទេសរបស់ខ្លួនថា សូមពិនិត្យឡើងវិញ នូវគម្រោងដែលបានអនុវត្តយកស្តង់ដារកម្រិតខ្ពស់ក្នុងការពិចារណាការធានាឲ្យបាននូវបរិស្ថាន និងសង្គម ដោយធ្វើការថ្លឹងថ្លែងជាមួយបទពិសោធន៍បរាជ័យពីអតីត របស់ធនាគារពិភពលោក ធនាគារអភិវឌ្ឍន៍អាស៊ី និងភ្នាក់ងារ/រដ្ឋាភិបាលម្ចាស់ជំនួយផ្សេងៗទៀត។

**ជូនចំពោះសហគមន៍មូលដ្ឋានដែលរស់នៅក្នុងអាងទន្លេ៖**

- ប្រសិនបើបរិស្ថាន រងការខូចខាតដោយសារគម្រោងគាំទ្រដោយរដ្ឋាភិបាល ឬភ្នាក់ងារអភិវឌ្ឍន៍នានា សហគមន៍មូលដ្ឋានអាចសហការគ្នាក្នុងចំណោមសហគមន៍គ្នាឯង ដើម្បីទាមទារឲ្យអ្នកបង្ក ទទួលខុសត្រូវ និងមកស្តារឡើងវិញចំពោះការខូចខាតនោះ។
- ជាជាងធ្វើដើម្បីតែភាពសុខស្រួល និងផលប្រយោជន៍សេដ្ឋកិច្ចរយៈពេលខ្លីនៃតំបន់ណាមួយ តាមរយៈការប្រើប្រាស់ធនធានដី និងទន្លេ វាមានភាពចំបាច់ណាស់ក្នុងការពិចារណាឲ្យបានល្អិតល្អន់ពីផលប៉ះពាល់របស់វាទៅលើបរិស្ថានសង្គម និងធម្មជាតិក្នុងតំបន់ទីជំរាល (watershed area) ទាំងមូល។ ឧទាហរណ៍

មិនត្រូវធ្វើការបំផ្ទុះផ្សេងៗដែលអាចបំផ្លាញដល់ធនធាន ជលផល បញ្ចៀសការប្រើប្រាស់ហួសកំណត់នូវធនធាន ដូចជាការកាប់ឈើច្រើនហួសហេតុ និងត្រូវគិតគូរពីផលប៉ះពាល់បរិស្ថាន នៅពេលធ្វើការស្ថាបនាផ្លូវថ្នល់ និងផ្លូវទឹកភូមិ។ ត្រូវមានទិសដៅ ធានាឲ្យបាននូវនិរន្តរភាពក្នុងការប្រើប្រាស់ធនធាន។

- ប្រមូលផ្តុំ និងចងក្រងនូវរាល់ចំណេះដឹង និងព័ត៌មានក្នុងមូលដ្ឋាន ស្តីពីធនធានធម្មជាតិ។ សហគមន៍អាចផ្តួចផ្តើមធ្វើផែនការ និងចុះអនុវត្តការងារអភិវឌ្ឍន៍ក្នុងតំបន់របស់ខ្លួន ដោយធ្វើយ៉ាងណា ធានាតុល្យភាពរវាងទិដ្ឋភាពបែបមូលដ្ឋាន និងទិដ្ឋភាពបែបវិទ្យាសាស្ត្រ។

## ជូនចំពោះអ្នកស្រាវជ្រាវ និងសារព័ត៌មានៈ

- សម្រាប់អ្នកស្រាវជ្រាវ ត្រូវសិក្សា និងស្វែងយល់ឲ្យបានស៊ីជំរៅតាមបែបវិទ្យាសាស្ត្រ អំពីបរិស្ថានធម្មជាតិរបស់អាងទន្លេមេគង្គ និងត្រូវប្រើប្រាស់លទ្ធផលរកឃើញរបស់ខ្លួន ឲ្យមានប្រយោជន៍ដល់សង្គម។ សម្រាប់សារព័ត៌មាន ត្រូវផ្សព្វផ្សាយពីរបបគំហើញថ្មីៗដល់ប្រជាជន ដោយប្រើប្រាស់មធ្យាបាយទាំងឡាយណា ដែលសាធារណជនទូទៅងាយយល់។

ទន្លេមេគង្គ ដែលជាជង្រុកជីវៈចម្រុះដ៏មានតម្លៃមហាសាល សមតែទទួលបានការអភិរក្ស ដើម្បីជាប្រយោជន៍ដល់មនុស្សគ្រប់រូបនៅទូទាំងសាកលលោក។ យើងខ្ញុំ នឹងខិតខំបន្តធ្វើការទៅមុខទៀត ដើម្បីឲ្យអនុសាសន៍ខាងលើ បានសម្រេច ទាំងនៅក្នុងសហគមន៍របស់យើងខ្ញុំផ្ទាល់ ទាំងក្នុងប្រទេស ព្រមទាំងក្នុងតំបន់ទាំងមូល។ យើងខ្ញុំសង្ឃឹមថា ពិភពលោកនឹងឮនូវសំលេង/សម្រែករបស់ពួកយើង។

សូមទទួលការគោរពរាប់អានដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ។

ថ្ងៃទី ១៤ ខែមិនា ឆ្នាំ ២០១៦

*Cambodia*

3S Rivers Protection Network (3SPN)

Cambodia Indigenous Youth Association (CIYA)

Cambodian Community Development (CCD-Kratie)

Cambodian Youth Network (CYN)

Fisheries Action Coalition Team (FACT)

Jesuit Service-Cambodia

Khmer Youth Empire (KYE)

NAK AKPHIVATH SAHAKUM (NAS)

Save Vulnerable Cambodians (SVC)

Social and Environmental Protection Youth (SEPY)

The NGO Forum on Cambodia

Tonle Sap Lake Waterkeeper

*Japan*

Biodiversity Information Box

Friends of the Earth Japan

Fukuoka NGO forum on ADB

Japan Center for a Sustainable Environment and Society (JACSES)

Mekong Watch

Ramsar Network Japan

*Korea*

Busan Green Trust

Busan River Network

Daecheoncheon Network

Energy and Climate Policy Institute for Just Transition (ECPI)

Geumjeong Mountain Association

Institute for Environment and Community Development Studies

Korea Federation for Environmental Movement (KFEM)

Korea River Network

Life Web

Women's Environmental Coalition

*Thailand*

Assembly of the Poor, Pak Mun Dam affected people

EarthRights International

Srisaket Province's Association of Community Based Freshwater Fisheries, Northeast Thailand